**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

*ថ្ងៃពុធ ១រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*
*រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦*

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៦០

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ឱ្យបានជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៦០ ដែលមានឥណប្រតិទាន ៧ថ្ងៃ ៩១ថ្ងៃ និង១៨២ថ្ងៃ នឹងត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០២៦។ ចំពោះការទូទាត់សម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី២៦០ គ្រប់ឥណប្រតិទាននឹងត្រូវធ្វើឡើងនៅក្នុងថ្ងៃដដែល។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះ មានដូចតទៅ៖

| | |
|---|---|
| -ពេលវេលាដាក់ដេញថ្លៃ | :ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ០៩:០០ ព្រឹក |
| -នីតិវិធីដេញថ្លៃ | :ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស) |
| -វត្ថុធានា | :NCD ឬ មូលបត្ររដ្ឋ ជាវត្ថុធានាត្រូវមានឥណប្រតិទានវែងជាង ឬ ស្មើនឹងឥណប្រតិទានរបស់ LPCO<br>គ្រឹះស្ថានអាចប្រើប្រាស់សមតុល្យក្នុងគណនីចរន្តជាវត្ថុធានាបាន |
| -ហៃខាត់លើវត្ថុធានាជាដុល្លារអាមេរិក | :៣% |
| -ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា | :២០០.០០០.០០០ (ពីររយលាន) រៀល |
| -ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា | :មិនកំណត់ |

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ និងថ្ងៃឥណប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | ថ្ងៃឥណប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា |
|---|---|---|---|
| ៧ថ្ងៃ(D07) | ១២ មីនា ២០២៦ | ២៥០.០០០.០០០.០០០ រៀល | ២,៥០% |
| ៩១ថ្ងៃ (D91) | ៤ មិថុនា ២០២៦ | ២០.០០០.០០០.០០០ រៀល | ៣,២៥% |
| ១៨២ថ្ងៃ (D182) | ៣ កញ្ញា ២០២៦ | ៣០.០០០.០០០.០០០ រៀល | ៣,៥០% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃនឹងធ្វើតាមរយៈថ្នាលធនាគារជាតិនៃកម្ពុជា (NBCP) តាមកាលវិភាគដែលបានកំណត់។ ក្នុងករណី NBCP មិនអាចអនុវត្តបាន គ្រឹះស្ថានត្រូវបញ្ជូនពាក្យសុំដេញថ្លៃតាមសារអេឡិចត្រូនិក marketoperations@nbc.gov.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានទីផ្សាររូបិយវត្ថុ ឱ្យបានមុនម៉ោង ០៩:០០ ព្រឹក នៅថ្ងៃដេញថ្លៃ។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសក្រោយបញ្ចប់ការដេញថ្លៃ នាថ្ងៃដដែល។ គ្រឹះស្ថានដែលដេញថ្លៃឈ្នះត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មាធិការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។


សូមទំនាក់ទំនង ៖ នាយកដ្ឋានទីផ្សាររូបិយវត្ថុ

លេខទូរស័ព្ទ : (៨៥៥-២៣) ៩៩០ ១៩០

សារអេឡិចត្រូនិក : markets.info@nbc.gov.kh


បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖

www.nbc.gov.kh

ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia

National Bank of Cambodia | nbccambodia

Natonal Bank of Cambodia | nationalbankofcambodia_